ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១៣ ០១៦ ៨៨២ ធ.ក

ភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ ឆ្នាំ២០១៦
## វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ៖ កាលានុវត្តភាព និង ហានិភ័យ

ធនាគារជាតិនៃកម្ពុជា មានក្តីសោមនស្សរីករាយ សូមជម្រាបជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា បន្ទាប់ពីបានអនុញ្ញាតឲ្យស្រាវជ្រាវលើប្រធានបទ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ៖ កាលានុវត្តភាព និងហានិភ័យ ធនាគារជាតិនៃកម្ពុជាបានទទួលនូវលទ្ធផលនៃការស្រាវជ្រាវជាបន្តបន្ទាប់ និងគ្រោងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៣ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង ៨:០០-១៧:០០ នៅសណ្ឋាគារ Raffles Hotel Le Royal, ភ្នំពេញ ។

សន្និសីទនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងរួមចំណែកអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅកម្ពុជា លើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់ការពិភាក្សា រវាងភាគីពាក់ព័ន្ធក្នុងចំណោមអ្នកស្រាវជ្រាវ អ្នកជំនាញ និងអ្នករៀបចំគោលនយោបាយ ដើម្បីផ្តល់ជាធាតុចូលទៅក្នុងការរៀបចំគោលនយោបាយចម្បងៗ សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព សមភាព និងបរិយាប័ន្ន ។

សេចក្តីដូចបានជម្រាបជូនខាងលើ ធនគារជាតិនៃកម្ពុជានឹងអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធឲ្យមកចូលរួមក្នុងកម្មវិធីខាងលើ ។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
855 12 785 799/ 855 17 707 709
nbccommunication@nbc.org.kh